**កម្ពុជា–ឡឥដ្ឋ– ពលកម្មកុមារដោយបង្ខំ**

មានរបាយការណ៍ ថាមនុស្សធំពេញវ័យ ត្រូវបានគេបង្ខំឱ្យធ្វើការក្នុងការផលិតឥដ្ឋនៅកម្ពុជា។ យោងតាមការស្រាវជ្រាវថ្មីៗនេះ ដែលធ្វើឡើងដោយស្ថាប័នឯករាជ្យ រកឃើញថា ប្រជាជនកម្ពុជារាប់ម៉ឺននាក់ ដែលមានចំណងបំណុល បានធ្វើការនៅតាមសិប្បកម្មឡឥដ្ឋ ដែលបើកដំណើរការជាង ៤៦០ កន្លែង នៅទូទាំងប្រទេស ដើម្បីជួយឆ្លើយតបទៅនឹងតម្រូវការឥដ្ឋ ដោយសារការរីកដុះដាល នៃសំណង់នៅក្នុងរាជធានី  ភ្នំពេញ។ មនុស្សធំពេញវ័យ ជាពិសេសកសិករ ជារឿយៗ ពួកគាត់មិនអាចសងបំណុលគេបានទេ ហើយពួកគាត់ទុកបំណុលទាំងនេះ នៅនឹងម្ចាស់ឡឥដ្ឋ ដែលផ្តល់ប្រាក់កម្ចីបន្ថែម ដើម្បីទូទាត់លើការចំណាយប្រចាំថ្ងៃ។ ប្រការនេះ ធ្វើឲ្យពួកគាត់ប្រឈមនឹងស្ថានភាពជាប់បំណុលបន្ថែម និងរើខ្លួនមិនរួចពីឡឥដ្ឋ។ ដោយសារតែថ្លៃការប្រាក់ខ្ពស់ ដែលគេគិតទៅលើប្រាក់កម្ចី ដែលបានផ្តល់ដោយម្ចាស់ឡឥដ្ឋ ទើបធ្វើឲ្យមនុស្សធំពេញវ័យ យល់ថាក្នុងមួយជីវិតនេះ ពួកគាត់មិនអាចសងបំណុលគេរួចឡើយ ហើយត្រូវបានបង្ខំឱ្យផ្ទេរបំណុល  ដែលពួកគាត់សងមិនទាន់រួចនោះ ទៅឲ្យកូនៗរបស់ពួកគាត់សងបន្ត ដែលប្រការនេះ បង្កើតបានទៅជាវដ្តនៃចំណងបំណុលពហុជំនាន់។ ការស្រាវជ្រាវ ក៏បានរកឃើញថា នៅរដូវវស្សា នៅពេលដែលឥដ្ឋក្រស្ងួត ហើយប្រាក់ចំណូលធ្លាក់ចុះ កម្មករមិនត្រូវបានអនុញ្ញាតឱ្យចាកចេញពីឡឥដ្ឋ ដើម្បីរកប្រភពចំណូលផ្សេងមកជំនួសឡើយ។ កម្មករក៏ត្រូវបានគេគំរាមចាប់ខ្លួន ឬបង្ខំឱ្យសងបំណុលបន្ថែម ប្រសិនបើពួកគាត់ព្យាយាមចាកចេញពីឡឥដ្ឋ ដោយមិនទាន់សងបំណុលអស់។